# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*យើងអាចតាក់តែង ឬរៀបចំការយល់ដឹង ក្រៅពីឯកសារ ដើម្បីឲ្យសាក្សីផ្តល់ សក្ខីកម្ម។ យើងនឹងថ្លឹងថ្លែងទៅលើទម្ងន់ ឬក៏និយាយពីតម្លៃនៃសក្ខីកម្មនេះ អាស្រ័យលើ អង្គជំនុំជម្រះជាអ្នកសម្រេច... តែពេលនេះ យើងត្រូវសួរព័ត៌មានផ្ទាល់ទៅកាន់សាក្សី ព្រោះសាក្សីមានព័ត៌មាន និងវត្តមាននៅចំពោះមុខតុលាការស្រាប់ហើយ។*

- លោក អេនឌ្រូ អ៊ីនូហ្ស៊ី
  មេធាវីអន្តរជាតិការពារក្តីឲជនជាប់ចោទ **នួន ជា**

## I. និដ្ឋភាពទូទៅ

ក្នុងការចូលរួមប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិអង្គជំនុំជម្រះ បានដំណើរការសវនាការតែ ៣ថ្ងៃ ប៉ុណ្ណោះនាសប្តាហ៍នេះ។ ថ្ងៃច័ន្ទ និងថ្ងៃអង្គារ សវនាការបន្តស្តាប់សក្ខីកម្មសាក្សី មាស វឿន ដែលជាទាហាន ខ្មែរក្រហមម្នាក់ និងក្រោយមក បានក្លាយជាបញ្ហាការរងនៃកងពលធំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ចំណែកឯរសៀលថ្ងៃអង្គារ អង្គជំនុំជម្រះបានឲ្យក្រឡាបញ្ជីអានអង្គហេតុដែលមាននៅក្នុងដីកាដំណោះស្រាយ ពាក់ព័ន្ធនឹងវាលពិឃាតទួលពោធិ៍ជ្រៃ បន្ថែមលើផ្នែកមាននៅក្នុងសវនាការវគ្គទី៣នៃសំណុំរឿង០០២/០១ ដែលបានអានកាលពីសប្តាហ៍មុន។[1] កាលពីថ្ងៃពុធ ដែលជាថ្ងៃចុងសប្តាហ៍ សហព្រះរាជអាជ្ញាបានចាប់ផ្តើម ដាក់បង្ហាញឯកសារទាក់ទងនឹងសវនាការវគ្គទី៣។

សវនាការរយៈពេល៣ថ្ងៃនេះ អង្គជំនុំជម្រះក៏បានចំណាយពេលវេលាដោះស្រាយនូវបញ្ហាច្បាប់ និង នីតិវិធី ដែលបានលើកឡើងរួមមានដូចជា៖ (ក) ការប្រើប្រាស់ឯកសារដែលទទួលបានពីការធ្វើទារុណកម្ម (ខ) នីតិវិធីក្នុងការ *“ដកចេញ”* នូវសេចក្តីថ្លែងការណ៍ពីកំណត់ហេតុរបស់សហចៅក្រមស៊ើបអង្កេត (គ) ការសួរដេញដោលស្តីពីការមិនធ្វើកំណត់ត្រាយោងលើឯកសារឬសេចក្តីថ្លែងការណ៍ពីមុនៗ (ឃ) ភាពជឿ ជាក់បាននៃកំណត់ហេតុស្តីពីកិច្ចសម្ភាសរបស់សហចៅក្រមស៊ើបអង្កេត និង (ង) សំណួរដែលមានចេតនា នាំមុខសាក្សី។ បន្ថែមលើនេះ ជនជាប់ចោទ **នួន ជា** ត្រូវបានអនុញ្ញាតិឲ្យបញ្ចេញជាមតិយោបល់ដើម្បីស្រាយ

បំភ្លឺអំពីអង្គហេតុនៅក្នុងដីកាដំណោះស្រាយ។

## II. សេចក្តីសង្ខេបសក្ខីកម្មរបស់សាក្សី មាស រឿន

សប្តាហ៍នេះ ភាគីបានបន្តសួរដេញដោលសាក្សី មាស រឿន ហៅ *"ស្វាយ រឿន"* (TCW-428)។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី - ចៅក្រមហ្សង់ ម៉ាក ឡាវែន៍ និង ក្រុមមេធាវីការពារក្តី បានសួរដេញដោលសាក្សីលើប្រធានបទដែលបានជជែកពិភាក្សាកាលពីសប្តាហ៍មុន ដើម្បីទទួលបានព័ត៌មានលម្អិតដោយផ្តោតជាពិសេសទៅលើ៖ ការយល់ដឹងផ្ទាល់ខ្លួនពីជនជាប់ចោទនានា - ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ - ប្រតិកម្មទៅលើជនជាតិថៃ និង វៀតណាមនៅតាមតំបន់ឆ្នេរសមុទ្រ - និង គោលនយោបាយទូទៅរបស់ខ្មែរក្រហម រួមបញ្ចូលទាំងការធ្វើទុក្ខបុកម្នេញលើអ្នកទោស និងការរៀបការដោយបង្ខំ។

### ក. តួនាទីសាក្សីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ផ្អែកតាមសក្ខីកម្មសាក្សីកាលពីសប្តាហ៍មុន បានឲ្យដឹងថាគាត់ត្រូវបានតែងតាំងជាបញ្ជាការរង នៃកងពលធំលេខ១ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ មេធាវីអន្តរជាតិការពារក្តីឲ **នួន ជា** លោក អេនឌ្រូ អ៊ីនូហ្ស៊ី បានចោទសួរទៅកាន់សាក្សីថា តើមានការអនុវត្តបែបណាខ្លះបានជាសាក្សី មាស រឿន អាចទទួលមុខងារក្នុងជួរកងទ័ពបានលឿនដូច្នេះ? សាក្សី មាស រឿន បានឆ្លើយថាគាត់មិនបានទទួល តំណែងឆាប់រហ័សដូចដែលលើកឡើងទេ ហើយតួនាទីរបស់គាត់មានដែនកំណត់ ទោះបីជាគាត់កាន់ តំណែងមួយខ្ពស់ក៏ដោយ។ គាត់បានរងរបួសដោយសារការពលីធ្វើសង្គ្រាម ហេតុនេះហើយបានជានៅពេលគាត់ជាសះស្បើយឡើងវិញ គាត់ត្រូវបានតែងតាំងជាអនុប្រធានកងពលធំលេខ១ ប្រចាំខេត្តកោះកុង។ ដំបូងឡើយសាក្សីបានបំពេញមុខងារជំនួសមុខឲ្យមេបញ្ជាការរង ក្នុងពេលដែលគាត់កំពុងទទួលការ ព្យាបាលនៅក្នុងមន្ទីរពេទ្យ។

### ខ. ការយល់ដឹងផ្ទាល់ខ្លួនពីជនជាប់ចោទនានា និងមន្ត្រីជាន់ខ្ពស់ផ្សេងទៀត

កាលពីសប្តាហ៍មុនក្នុងសក្ខីកម្មរបស់សាក្សី មាស រឿន មិនបានរំឭកអ្វីពីជនជាប់ចោទ **អៀង សារី** ទេ។ សាក្សីបានបញ្ជាក់ថា គាត់ក៏មិនដែលបានជួបជនជាប់ចោទ **នួន ជា** ដោយផ្ទាល់ ហើយក៏មិនបានដឹងពីតួនាទីរបស់គាត់ជាក់លាក់ដែរ។ គាត់គ្រាន់តែទទួលដំណឹងថា **នួន ជា** គឺ ជាសមាជិកម្នាក់នៅក្នុងជួរអគ្គសេនាធិការបក្ស។ យ៉ាងណាក្តី ចម្លើយនេះមានភាពប្រទាំងប្រទិសនឹងចម្លើយដែលគាត់បានឆ្លើយជាមួយសហចៅក្រមស៊ើបអង្កេត ដែលកាលពីពេលនោះ សាក្សីបានបញ្ជាក់ថាគាត់ពិតជាបានឮពីឈ្មោះ **នួន ជា** ប៉ុន្តែគឺនៅក្រោយថ្ងៃរំដោះទីក្រុងភ្នំពេញបានហើយ។ ប្រការនេះ ធ្វើឲ្យលោក សុន អារុណ ដែលជាមេធាវីជាតិការពារក្តីលោក **នួន ជា** សួរទៅកាន់សាក្សីថា តើគាត់បដិសេធចម្លើយរបស់គាត់ដែលបានឆ្លើយជាមួយសហចៅក្រមស៊ើបអង្កេតត្រង់ចំណុចដែលថា ខ្លួនបានដឹងពីតួនាទីរបស់ **នួន ជា** នៅក្នុងសម័យសង្គ្រាម? សាក្សី មាស រឿន បានបញ្ជាក់ថា គាត់សូមដកចម្លើយនេះវិញ។ (*មើល III.ខ.*)

ដោយមានភាពស៊ីសង្វាក់ជាមួយនឹងចម្លើយមុនៗ សាក្សីនៅតែចង្អុលបង្ហាញថា គាត់បានស្គាល់

ជនជាប់ចោទ **ខៀវ សំផន** និងបានរៀបរាប់ថា មានគ្រាមួយ នៅពេលដែលគាត់បានក្លាយជាសមាជិក នៃសម្ព័ន្ធយុវជនស្នេហាជាតិកាលពីឆ្នាំ១៩៦៨ លោក **ខៀវ សំផន** បានគៀសខ្លួនចេញពីទីក្រុងភ្នំពេញទៅ តំបន់សុវត្ថិភាពមួយក្នុងព្រៃ។ នាពេលនោះសាក្សី មាស រឿន គឺជាសមាជិកម្នាក់ក្នុងចំណោមយុវជនផ្សេងៗ ទៀតនៃក្រុមសម្ព័ន្ធយុវជនស្នេហាជាតិដែលត្រូវបានចាត់តាំងឲ្យធ្វើការការពារដល់ លោក **ខៀវ សំផន** ។ លោក គង់ សំអុន ដែលជាមេធាវីជាតិការពារក្តីជនជាប់ចោទ **ខៀវ សំផន** បានធ្វើការកត់សម្គាល់ថា ក្នុងឆ្នាំ១៩៦៨ អតីតព្រះមហាក្សត្រ **នរោត្តម សីហនុ** បានប្រកាសផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ដល់បុគ្គលណា ដែលផ្តល់ដំណឹងពីទីតាំងលាក់ខ្លួនរបស់ **ខៀវ សំផន** និងបានចោទសួរសាក្សី មាស រឿន ថាហេតុអ្វីបានជាគាត់មិនផ្តល់ព័ត៌មាននេះទៅរដ្ឋាភិបាលក្រុងភ្នំពេញដើម្បីទទួលបានប្រាក់រង្វាន់? សាក្សីបាន ឆ្លើយតបថា នាពេលនោះ អាចមានក្រុមស៊ើបការណ៍នៅក្នុងចលនាបដិវត្តន៍ ដូច្នេះគាត់មិនហ៊ានផ្តល់ព័ត៌មាន អ្វីពី លោក **ខៀវ សំផន** ទេ។

សាក្សី មាស រឿន ក៏បានទាក់ទងដោយផ្ទាល់ជាមួយជនជាប់ចោទ **ខៀវ សំផន** ក្នុងចន្លោះខែសីហា ១៩៧៨ ដល់ខែមករា ១៩៧៩ ខណៈពេលដែល លោក **ខៀវ សំផន** បានស្នើសុំឲ្យសាក្សីជួយមើលថែទាំ ឪពុកម្តាយចាស់ៗរបស់ខ្លួន និងក៏ជាអ្នកស៊ើបការណ៍ពីបញ្ហាទិន្នផលស្រូវ ក៏ដូចជាការចែកចាយសម្ភារៈ ផ្គត់ផ្គង់នៅភូមិភាគឧត្តរ។ គ្រានោះ សាក្សីដឹងត្រឹមថា លោក **ខៀវ សំផន** ទទួលបន្ទុកលើតំបន់ស្វយ័ត ១០៣។ ក្រៅពីនោះ សាក្សីមិនបានដឹងពីតួនាទីផ្សេងទៀតរបស់ជនជាប់ចោទ **ខៀវ សំផន** ឡើយ។ ជាងនេះទៀត សាក្សីបានឆ្លើយឆ្លងសារទូរលេខជាមួយជនជាប់ចោទរូបនេះ នៅក្នុងខែសីហា និងខែកញ្ញា ១៩៧៨ ពីព្រោះនាពេលនោះ កងទ័ពវៀតណាមបានខិតចូលកៀក និងបានកាត់ផ្តាច់ប្រព័ន្ធទំនាក់ទំនង ពីតំបន់ព្រះវិហារ និង មជ្ឈិម។

សាក្សីក៏បានស្គាល់ និងមានទំនាក់ទំនងជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀតផងដែរ។ ដំបូងឡើយ កាលនៅក្នុងព្រៃ សាក្សីបានរៀនសូត្រពីយុត្តិសាស្ត្រសង្គ្រាមពី *"បញ្ញាជន និងមេដឹកនាំផ្សេងៗដូចជា ហ៊ូ នឹម និង តាគ្រឹន"* ឧទាហរណ៍រួមមានដូចជា បញ្ហាជាតិនិយម និងការប្រយុទ្ធប្រឆាំងនឹមអាណានិគមបារាំង ក៏ដូចជាពួកចក្រពត្តិនិយម។ សាក្សីបានថ្លែងថា ក្រោយមក ហ៊ូ នឹម ត្រូវបានចាប់ខ្លួន និងត្រូវបានសម្លាប់ ដោយសារតែគាត់មានគំនិតផ្ទុយពីទស្សនៈអង្គការចំពោះការចរាចរលុយកាក់ឡើងវិញ។

ឆ្លើយតបទៅនឹងសំណួររបស់មេធាវី អ៊ីនូហ្ស៊ី សាក្សីបានថ្លែងថា តា ម៉ុក ដែលជាប្រធានភូមិភាគ បស្ចិម និងជាសមាជិកនៃអគ្គសេនាធិការ គឺជាអ្នក *"មានអំណាចខ្លាំង និងផ្តាច់ការ ហើយគាត់អាចសម្រេច លើគ្រប់ករណី។ ជាក់ស្តែងខ្ញុំធ្វើតាមបញ្ជាដោយឥតប្រកែក។"* សាក្សី មាស រឿន បានផ្តល់សក្ខីកម្មថា គាត់បានស្គាល់ តា ម៉ុក តាំងពីគាត់ចូលព្រៃលើកដំបូង។ តា ម៉ុក គឺជាអ្នកដែលបានជ្រើសរើសយក សាក្សីឲ្យចូលជាសមាជិកសម្ព័ន្ធយុវជន និងបានចាត់តាំងតួនាទីគាត់ជាកងការពារកម្មាភិបាលនានា។ សាក្សី បានថ្លែងថា *"តាម៉ុក ដើរគ្រប់កន្លែងទាំងអស់ និងនៅកន្លែងណាក៏ឃើញគាត់ដែរ។*

## គ. ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ

សាក្សីបានរៀបរាប់ថាក្នុងរយៈពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គាត់បានឈរជើង នៅមន្ទីរពេទ្យមួយ ពីព្រោះប្រជាជនបានសម្រុកចូលអាគារឱសថស្ថានដើម្បីយកថ្នាំពេទ្យ។ សាក្សីបានឈរ

ការពារប្រជាជនមិនឲ្យចូល ព្រោះអាចមុតអំបែងកញ្ចក់ និងបានកែនពួកគេឲ្យចាកចេញពីទីនោះ។ សាក្សីបានថ្លែងថា គាត់មិនបានឃើញអ្នកជម្ងឺណាម្នាក់ទេ ពីព្រោះគាត់បានចូលត្រឹមឃ្លាំងដាក់ថ្នាំ ដែលមិនមែនជាកន្លែងទទួលអ្នកជម្ងឺ។ សាក្សីក៏បានផ្តល់ព័ត៌មានបន្ថែមលើ សក្ខីកម្មខ្លួនកាលពីសប្តាហ៍មុន ទាក់ទងនឹងសកម្មភាពរបស់គាត់ក្រោយថ្ងៃនៃ *"ការរំដោះ"* ទីក្រុងភ្នំពេញ និងបានថ្លែងថា នៅពេលដែលរូបគាត់ និងកងវរសេនាធំ ត្រូវបានដកទៅកាន់ស្រុកកំពង់ត្រាចក្នុងខេត្តកំពត ពួកគេបានទទួលបន្ទុកផ្នែកការពារសកម្មភាពយោធា និង ការផលិតស្រូវអង្ករ។

## ឃ. ប្រតកម្មជាមួយជនជាតថៃ និងវៀតណាមនៅតាមតំបន់ឆ្នេរ

សាក្សីបានបរិយាយយ៉ាងល្អិតល្អន់ថា កងពលធំរបស់គាត់ទទួលបន្ទុកការពារមិនឲ្យទូកអ្នកនេសាទថៃ និងវៀតណាម រំលោភចូលដែនទឹកនៃប្រទេសកម្ពុជាឡើយ។ គាត់បានអះអាងថា គាត់បានចេញបញ្ជាឲ្យចាប់ទូកនេសាទទាំងនោះ ហើយកូនចៅរបស់គាត់ធ្វើការបានយ៉ាងជោគជ័យដោយចាប់បានទូកច្រើនជាងពាក់កណ្តាលនៃទូកដែលបានចូលចតក្នុងដែនទឹកកម្ពុជា។ សាក្សីមិនបានដឹងថា មានអ្វីកើតឡើងចំពោះមនុស្សដែលត្រូវបានចាប់ខ្លួននោះទេ ហើយក៏មិនដឹងថា បញ្ហានេះត្រូវបានរាយការណ៍ទៅអគ្គសេនាធិការ ឬទុកនៅត្រឹមថ្នាក់កងពល។

សាក្សីបានគូសបញ្ជាក់ពីឈ្មោះកោះមួយចំនួនដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់ និងមួយចំនួនទៀត ស្ថិតក្រោមការគ្រប់គ្រងពីកងពលធំលេខ៣ ដោយមានមេបញ្ជាការម្នាក់ឈ្មោះ មាស មុត។ សាក្សី មាស វឿន បានទទួលបន្ទុកលើតំបន់កោះកុង រួមមាន កោះកុង និងកោះតូចៗមួយចំនួនទៀត ដូចជា កោះ*សណ្តែក* កោះ*កាពិ* កោះ*យ៉* កោះ*សាឡៅ* កោះ*សាន់ចារ៉* និងកោះ*ឆ្លាម* ព្រមទាំងតំបន់ឆ្នេរក្រសោក។ ចំណែកឯកងពលធំលេខ៣ ទទួលបន្ទុកគ្រប់គ្រងកោះជិតខាងផ្សេងទៀត រួមមាន កោះ*ត្រល់* កោះ*អាចម៍សេះ* កោះ*ពូឡូវៃ* និង កោះ*ព្រាន*។ សាក្សីក៏បានរៀបរាប់ពីរបៀបដែលកងទ័ពវៀតណាមបានយកកោះ*ពូឡូវៃ* ដែលជាកោះស្ថិតក្រោមការគ្រប់គ្រងរបស់ មាស មុត និងកងពលធំលេខ៣។ សាក្សីបានដឹងពីព័ត៌មានលម្អិតនៃការដណ្តើមយកកោះនេះពីកូនទាហានរបស់ខ្លួន។ គាត់បានថ្លែងបន្តទៀតថា នៅលើកោះក្បែរៗនោះសុទ្ធតែទាហានវៀតណាមបានចូលមកបោះទីតាំងឈរជើង និងមិនមានជនស៊ីវិលរស់នៅឡើយ។

មេធាវី **អ៊ីនូហ្ស៊ី** ក៏បានព្យាយាមចូលលម្អិត និងកាន់តែស៊ីជម្រៅ ដើម្បីបង្ហាញថា សាក្សីមានចំណេះដឹងគ្រប់គ្រាន់ និងច្បាស់លាស់ពាក់ព័ន្ធនឹងបញ្ហាព្រំដែនកម្ពុជា-ថៃ។ ជាការឆ្លើយតបភ្លាមៗនោះ សាក្សីបានបញ្ជាក់ថា គាត់ស្គាល់ច្បាស់តំបន់ដែលនៅតាមបណ្តោយព្រំដែន បូករួមទាំងភូមិភាគ និងទីក្រុងតូចៗមួយចំនួននៅខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ដូចជាជំរុំ*កងរ៉ា* ស្រុក*ថ្មពួក* ជំរុំ*តាង៉ុក* ភ្នំ*ឆ័ត្រ* និងស្រុក*ម៉ាឡៃ* ជាដើម។ ទោះបីជាយ៉ាងណាមេធាវី **អ៊ីនូហ្ស៊ី** មិនបានបន្តសួរ សំណួរដេញដោលលើបញ្ហានេះទេ។

## ង. ចំណេះដឹងពាក់ព័ន្ធនឹងគោលនយោបាយបក្សរបស់ខ្មែរក្រហម

សាក្សីបានដឹងពីគម្រោងផែនការកម្ទេចខ្មាំងនៅក្នុងជួរកងទ័ព ពិសេសបុគ្គលដែលជាប់ខ្សែស្រឡាយវៀតណាម ចិន និង គិញ *ស៊ី.អាយ.អេ* ។ សាក្សី មាស វឿន បានថ្លែងថា ពាក់ព័ន្ធនឹងបញ្ហានេះ ប្រជាជន

ប្រមាណជា៥៥០នាក់ត្រូវបានកម្ទេច ប៉ុន្តែគាត់មិនបានដឹងថាតើគម្រោងនេះត្រូវបានធ្វើចប់សព្វគ្រប់នោះទេ។

សាក្សីបានអះអាងថា គាត់មិនបានដឹងថាមានការប្រព្រឹត្តបែបណាទៅលើជនដែលត្រូវគេចាប់បាន ហើយព្យាយាមរត់គេច ហើយក៏មិនបានដឹងថាមានការប្រព្រឹត្តដូចម្តេចដែរទៅលើជនជាតិវៀតណាម និង ជនជាតិថៃ ដែលត្រូវបានចាប់ខ្លួនមក ប៉ុន្តែដឹងត្រឹមតែថា ពួកគេត្រូវបានបញ្ជូនទៅ *"សមរភូមិក្រោយ។"* ទោះបីជាមានឯកសារមួយចំនួន ដែលសហមេធាវីនាំមុខអន្តរជាតិ អេលីហ្សាបេត ស៊ីម៉ុនណូហ្វត បានអាននៅក្នុងសវនាការដើម្បីសួរទៅកាន់សាក្សី ក៏សាក្សីនៅតែថ្លែងថា គាត់មិនបានដឹងពីការប្រព្រឹត្ត ឃោរឃៅតាមរយៈការធ្វើទារុណកម្ម និងសម្លាប់ជនរត់គេចខ្លួននៅភូមិភាគរបស់គាត់ទេ។

សាក្សីក៏បានចង្អុលបង្ហាញថា នៅពេលដែលគាត់ចុះទៅមើលមន្ទីរសន្តិសុខនៅខេត្តសៀមរាប ដើម្បី ទៅជួយរំដោះយកប្អូនស្រីថ្លៃរបស់ជនជាប់ចោទ **ខៀវ សំផន** គាត់មិនបានដឹងពីការបោសសំអាត ឬផែនការ បោសសម្អាតណាមួយនៅភូមិភាគពាយព្យ។ ទោះបីជាយ៉ាងណា សាក្សី មាស វឿន បានកត់សម្គាល់ថា ប្រជាជននៅភូមិភាគពាយព្យមានការភ័យខ្លាចចំពោះការចាប់ខ្លួន។ រីឯស្បៀងអាហារ និងសម្ភារៈផ្គត់ផ្គង់ ផ្សេងៗ ដូចជា អំបិល មុង និងភួយ ដែលបានបញ្ជូនទៅ បែរជាឥតប្រយោជន៍ និងត្រូវបានរក្សាទុកតែក្នុង ឃ្លាំង ជាជាង ផ្តល់ឲ្យប្រជាជនប្រើប្រាស់។ គាត់មិនបានរាយការណ៍ពីស្ថានភាពលំបាកវេទនានេះទៅថ្នាក់លើ គឺ លោក **ខៀវ សំផន** នោះទេ ពីព្រោះព័ត៌មានទាំងនេះមិនស្ថិតក្រោមការដាក់ឲ្យអនុវត្តផ្ទាល់នៅក្នុងតំបន់ គោលដៅរបស់គាត់។

ចំពោះបញ្ហារៀបអាពាហ៍ពិពាហ៍ សាក្សីបានថ្លែងថា គាត់បានផ្តល់ការអនុញ្ញាតឲ្យមានការរៀបការ នៅក្នុងកងពលខ្លួន ចំពោះគូស្វាមីភរិយាដែលស្ម័គ្រចិត្ត ហើយគាត់មិនធ្លាប់ឮពីការសម្លាប់ខ្លួនដោយការបង្ខំឲ្យ រៀបការកើតឡើងក្នុងភូមិភាគរបស់គាត់ទេ។ សាក្សីបានបន្ថែមថា *"ក្នុងពិធីរៀបការពុំមានភ្លេងភ្លាត់ ឬផ្កាផ្ទីអ្វីទេ"* ប៉ុន្តែគូភាគីអាចជ្រើសរើសបុគ្គលដែលខ្លួនស្រឡាញ់ពេញចិត្តនៅក្នុងភូមិភាគរបស់គាត់។

## ច. ឥរិយាបថ និង ភាពគួរឲ្យជឿជាក់បានរបស់សាក្សី

សាក្សីមានសភាពស្ងប់ស្ងៀម តែពោរពេញដោយភាពជឿជាក់ និងបានផ្តល់សក្ខីកម្មយ៉ាងច្បាស់ លាស់។ ទោះបីជាយ៉ាងណា មេធាវី ម៉ែខល កាណាវាស ដែលជាមេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ **អៀង សារី** បានចោទសួរពីភាពជឿជាក់នៃសេចក្តីថ្លែងការណ៍របស់សាក្សីនៅដំណាក់កាលសហចៅក្រម ស៊ើបអង្កេត។ មេធាវី កាណាវាស បានធ្វើការកត់សម្គាល់លើអត្ថបទសង្ខេបរបស់សហចៅក្រមស៊ើបអង្កេតថា កិច្ចសម្ភាសបានចាប់ផ្តើមពីម៉ោង ១០:២០ នាទីព្រឹក និងបញ្ចប់នៅវេលាម៉ោង ៥:៣០នាទីល្ងាច ដូចនេះ រយៈពេលសរុបប្រហែលជា ៧ម៉ោង ប៉ុន្តែមេធាវីការពារក្តីបានទទួលខ្សែអាត់សម្លេងដែលមានរយៈពេលតែ ២ម៉ោងកន្លះប៉ុណ្ណោះ។ ជាងនេះទៀត ប្រពន្ធរបស់សាក្សី មាស វឿន ក៏មានវត្តមាននៅក្នុងកិច្ចសម្ភាសនោះ ដែរ *"ក្នុងការជួយរំឭកការចងចាំ"* របស់សាក្សី។ *(សូមមើលផ្នែកទី III.ឃ)*

## III. បញ្ហាច្បាប់ និងនិតិវិធី

ទោះបីជាសវនាការបានប្រព្រឹត្តទៅតែចំនួនបីថ្ងៃក៏ដោយ ក៏បញ្ហាច្បាប់ និងនីតិវិធីជាច្រើនបានកើត

ឡើងនាសប្តាហ៍នេះ។ ភាគីបានតវ៉ាពីៈ (ក) ការប្រើប្រាស់ឯកសារដែលទទួលបានពីការធ្វើទារុណកម្ម (ខ) នីតិវិធីក្នុងការ *"ដកចេញ"* នូវសេចក្តីថ្លែងការណ៍ដែលបានពីការធ្វើកំណត់ហេតុរបស់សហចៅក្រមស៊ើបអង្កេត (គ) ការសួរដេញដោលដោយមិនបានយោងលើឯកសារ ឬសេចក្តីថ្លែងការណ៍មុនៗ (ឃ) ភាពជឿជាក់នៃកំណត់ហេតុ កិច្ចសម្ភាសរបស់សហចៅក្រមស៊ើបអង្កេត និង (ង) សំណួរដែលមានចេតនានាំមុខសាក្សី។ បន្ថែមលើនេះ ជនជាប់ចោទ **នួន ជា** ត្រូវបានអនុញ្ញាតឲ្យបញ្ចេញជាមតិយោបល់ ដើម្បីធ្វើការឆ្លើយតបទៅនឹងអង្គហេតុនៅក្នុងដីកាដំណោះស្រាយ ដែលបានអានដោយក្រឡាបញ្ជី។

## ក. បញ្ហាពាក់ព័ន្ធនឹងការប្រើប្រាស់ឯកសារដែលបានពីការធ្វើទារុណកម្ម

ជាថ្មីម្តងទៀត ភាគីបានជជែកដេញដោលពីការប្រើប្រាស់ចម្លើយសារភាពដែលទទួលបានពីការធ្វើទារុណកម្ម។[2] នៅថ្ងៃច័ន្ទ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ បានសួរដេញដោលសាក្សី មាស វឿន ដោយយោងទៅលើចម្លើយសារភាពរបស់អ្នកទោសនៅមន្ទីរ ស-២១។ មេធាវី កាណាវ៉ាស បានជំទាស់ទៅនឹងវិធីសាស្ត្រនេះ ដោយបានលើកនូវសេចក្តីសំអាងរបស់ខ្លួនថាៈ

> *ចៅក្រមហាក់ដូចជាលើកឡើងពីខ្លឹមសារនៃចម្លើយសារភាព។ ដូច្នេះ វាដូចជាមានការអនុវត្តន៍ស្តង់ដារពីរនៅទីនេះ។ ខ្ញុំមិនដឹងថាវិធាននេះយ៉ាងម៉េចទេ ក៏ប៉ុន្តែខ្ញុំសូមឲមានការបញ្ជាក់។*

មេធាវី អ៊ីនូហ្ស៊ែ ដែលជាមេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ **នួន ជា** បានគាំទ្រនូវការជំទាស់របស់មេធាវីការពារក្តីឲ្យលោក **អៀង សារី**។ ជាការឆ្លើយតប ចៅក្រម ឡាវែន៍ បានថ្លែងថា *"... ខ្ញុំគ្រាន់តែចង់ដឹងថាតើសាក្សីស្គាល់បុគ្គលដែលមាននៅក្នុងចម្លើយសារភាពនេះទេ ... ហើយជាងនេះសម្រង់វាស្ថិតនៅក្នុងបញ្ជីមួយផ្សេងទៀត"* ដោយលោកចៅក្រមបានបញ្ជាក់ថា គឺជាបញ្ជីឈ្មោះពាក់ព័ន្ធនឹងថ្នាក់ដឹកនាំខ្មែរក្រហមដែលចេញពីប្រភពមួយផ្សេង មិនមែនមកពីចម្លើយសារភាពទេ។ ជាបន្ទាប់ ចៅក្រម ឡាវែន៍ បានចោទសួរសំណួរបន្ថែមទៅកាន់សាក្សី។ អង្គជំនុំជម្រះមិនបានចេញសេចក្តីសម្រេច ឬផ្តល់មតិយោបល់លើបញ្ហានេះទេ។ កាលពីសប្តាហ៍មុន អង្គជំនុំជម្រះតាមរយៈចៅក្រម ខាតរ៉ាយថ៍ បានថ្លែងថា អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យប្រើប្រាស់ចម្លើយសារភាពដែលទទួលបានពីការធ្វើទារុណកម្ម ព្រោះផ្ទុយនឹងអនុសញ្ញាស្តីពីការប្រឆាំងការធ្វើទារុណកម្ម ក្នុងការសួរដេញដោលសាក្សី។ ទោះបីជាយ៉ាងណា វាហាក់ដូចជាបង្ហាញពីតម្រូវការនៃសេចក្តីសម្រេចមួយដ៏ជាក់លាក់ និងត្រឹមត្រូវទាក់ទងនឹងបញ្ហានេះ។

## ខ. នីតិវិធីក្នុងការដកចេញនូវសេចក្តីថ្លែងការណ៍ពីកំណត់ហេតុរបស់សហចៅក្រមស៊ើបអង្កេត

នៅពេលដែលមេធាវី សុន អារុណ បានស្នើសុំការបញ្ជាក់ពីសាក្សី ថាតើគាត់ *"ជំទាស់"* មិនទទួលស្គាល់ចម្លើយនៅក្នុងកំណត់ហេតុបទសម្ភាសខ្លួននៅដំណាក់កាលសហចៅក្រមស៊ើបអង្កេត ត្រង់ចំណុចថាសាក្សីបានដឹងពីតួនាទីរបស់ជនជាប់ចោទ **នួន ជា** នៅក្នុងអំឡុងពេលសង្គ្រាម *(សូមមើល II.ខ)*។

ព្រះរាជអាជ្ញា ថារិក អាប់ឧលឡាក់ បានជំទាស់ទៅនឹងសំណើនេះ ដោយបានទាញហេតុផលថា ពុំមានវិធានដែលកំណត់ពីការដកចេញនូវសេចក្តីថ្លែងការណ៍**ដែលបានពីការធ្វើ**កំណត់ហេតុនោះទេ។ ព្រះរាជអាជ្ញាអាប់ឧលឡាក់ អះអាងថាលោកមេធាវីអាចត្រឹមតែចោទសួរថាតើសេចក្តីថ្លែងរបស់គាត់ត្រឹមត្រូវ ឬមិនត្រឹមត្រូវប៉ុណ្ណោះ។ មេធាវី សុន អារុណ បានឆ្លើយតបថា សហព្រះរាជអាជ្ញា និងភាគី បានប្រើប្រាស់សេចក្តីថ្លែងការណ៍នេះ ដូចនេះសាក្សីក៏មានសិទ្ធិក្នុងការផ្តល់ជាមតិយោបល់ ថាតើគាត់ចង់រក្សាទុក ឬដកចេញសេចក្តីថ្លែងការណ៍ដែលបានពីកំណត់ហេតុនៃការផ្តល់ចំលើយដល់ចៅក្រមស៊ើបអង្កេត។

មេធាវី កាណាវ៉ាស បានលើកជាយោបល់ថា សេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា គឺមិនត្រឹមត្រូវទេ និងបានអះអាងថា សាក្សីមានសិទ្ធិក្នុងការផ្តល់មតិយោបល់ និងធ្វើការបញ្ជាក់ ឬបដិសេធចម្លើយជាក់លាក់ណាមួយ។ លោកមេធាវីក៏បានលើកថា មេធាវីការពារក្តីលោក **នួន ជា** អាច**នឹង**ភ័ន្តច្រលំក្នុង ការប្រើវាក្យស័ព្ទនៅពេលធ្វើការចោទសួរ ដោយបានសួរថា តើសាក្សីចង់ *"ជំទាស់"* នឹងសេចក្តីថ្លែងការណ៍របស់ខ្លួនដែលមាននៅក្នុងកំណត់ហេតុ ជាជាងការប្រើពាក្យថាតើសាក្សីចង់ *"ដកចេញ"* ពីសេចក្តីថ្លែងខ្លួនដែលមានក្នុងកំណត់ហេតុ។ មេធាវី គង់ សំអុន បានសំដែងការគាំទ្រចំពោះអង្គហេតុរបស់មេធាវីការពារក្តី **អៀង សារី**។ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី លោក ពេជ អង្គ ក៏បានផ្តល់ជាយោបល់ថា កំណត់ហេតុនៃកិច្ចសម្ភាសន៍ត្រូវបានអានឲ្យសាក្សីស្តាប់ក្រោយពេលសម្ភាសចប់ហើយសាក្សីទាំងនោះ ក៏បានបញ្ជាក់ពីភាពត្រឹមត្រូវរបស់វាដែរ។[3] មេធាវី ពេជ អង្ុគ បានថ្លែងថា អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការពិចារណាទៅលើភាពជឿជាក់នៃសេចក្តីថ្លែងការណ៍នោះ។

អង្គជំនុំជម្រះតាមរយៈចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ បានថ្លែងថា ពុំមានវិធានដែលកំណត់ពីការជំទាស់លើសេចក្តីថ្លែងការណ៍នៅក្នុងកំណត់ហេតុរបស់ចៅក្រមស៊ើបអង្កេតទេ តែទោះជាយ៉ាងណា អង្គជំនុំជម្រះនឹងធ្វើការពិចារណាទៅលើភាពមិនស៊ីសង្វាក់នេះ ក្នុងដំណាក់កាលវាយតម្លៃលើភស្តុតាង។ សេចក្តីសម្រេចនេះ គឺដូចទៅនឹងសេចក្តីសម្រេចកាលពីសប្តាហ៍មុន នៅពេលដែលចៅក្រម **ខាតវ៉ាយថ៍** បានលើកឡើងថា *"វិធានច្បាប់ដែលតុលាការនេះកំពុងអនុវត្ត ពុំមានចែងពីសិទ្ធិក្នុងការជំទាស់លើសេចក្តីថ្លែងការណ៍របស់ខ្លួនឯងឡើយ។"*[4] ទោះជាយ៉ាងណាក្តី តាមការចង្អុលបង្ហាញរបស់ មេធាវី អ៊ីនូហ្ស៊ី វាហាក់ដូចជាថាភាគីត្រូវការការបញ្ជាក់បន្ថែម ថាតើឯកសារ ឬកំណត់ហេតុណាខ្លះ ដែលអាចគ្របដណ្តប់ឲ្យអនុវត្តបានបើយោងតាម សេចក្តីសម្រេចនេះ ពីព្រោះកាលពីសប្តាហ៍មុន អង្គជំនុំជម្រះបានចេញសេចក្តីបង្គាប់នូវ *"ពាក្យមួយចំនួន"* ដែល *"មិនបានចុះក្នុងកំណត់ត្រាត្រឹមត្រូវ"* ឲ្យដកចេញពីប្រតិចារិកតុលាការនៅចំពោះមុខអង្គ ជំនុំជម្រះ។ *(សូមមើល IV.**គ**)*

## គ. ការសួរដេញដោលដោយគ្មានឯកសារយោង ឬសេចក្តីថ្លែងការណ៍មុនៗ

នៅថ្ងៃអង្គារ ព្រះរាជអាជ្ញា **ថារិក អាប់ឧលឡាក់** បានធ្វើការជំទាស់ទៅនឹងការតាំងសំណួររបស់មេធាវី **អ៊ីនូហ្ស៊ី** នៅពេលដែលលោកមេធាវីចោទសួរសាក្សីថា *"តើលោកបានដឹងទេ តើថា តាម៉ុក និង មាសមុត ត្រូវបាន កំណត់ថាមានសិទ្ធិសម្រេចដោយផ្ទាល់* ដោយមិនចាំបាច់*ពិគ្រោះ*យោបល់ពីមជ្ឈិមបក្ស *ក្នុងការចេញបញ្ជាឲ្យមានការកម្ទេច។"*

ព្រះរាជអាជ្ញា អាប់ឧលឡាក់ បានលើកទឡ្ហីករណ៍ថា សំណួរនេះ គឺមិនសមស្របទេ ពីព្រោះវាមិន

បានយោង ទៅលើឯកសារ ឬសេចក្តីថ្លែងការណ៍ជាក់លាក់ណាមួយ។ មេធាវី អ៊ីនូហ្ស៊ី បានបដិសេធនូវការជំទាស់នេះ ដោយអះអាងថា សំណួររបស់គាត់ គឺផ្តោតសំខាន់ទៅលើចំណេះដឹងផ្ទាល់ខ្លួនរបស់សាក្សីដែលសាក្សីជាបុគ្គលម្នាក់ បានឃើញព្រឹត្តការណ៍ផ្ទាល់ភ្នែកក្នុងរបបនោះ។ លោកមេធាវីបានបន្តថា សាក្សីអាចបញ្ជាក់ពីបញ្ហាទាំងនេះដោយមិនចាំបាច់យោងលើឯកសារណាមួយឡើយ។ មេធាវី អ៊ីនូហ្ស៊ី បានថ្លែងថា នៅសប្តាហ៍ខាងមុខតុលាការនឹងធ្វើសវនាការលើឯកសារ ដូច្នេះអាចជាពេលដែលភាគីអាចពិភាក្សាលើឯកសារដោយសេរី ប៉ុន្តែ *"ឥឡូវ យើងមានសាក្សីនៅចំពោះមុខ ដូច្នេះយើងសួរព័ត៌មានផ្ទាល់ទៅកាន់សាក្សីថាតើសាក្សីនឹងឆ្លើយបែបណា។"*

អង្គជំនុំជម្រះបានសម្រេចតាមការជំទាស់របស់សហព្រះរាជអាជ្ញា។ លោកស្រីចៅក្រម **ខាត់រ៉ាយថ៍** បានពន្យល់ថា សំណួរទាំងឡាយដែលមិនយោងលើឯកសារជាក់លាក់ ឬភស្តុតាងផ្សេងៗ គឺមិនអាចទទួលយកបានទេ ពីព្រោះបើគ្មានមូលដ្ឋានជាក់លាក់ អង្គជំនុំជម្រះនឹងមិនមានអ្វីជាសម្អាងចំពោះការសួរដេញដោលដោយផ្ទាល់មាត់ឡើយ។

> *អង្គជំនុំជម្រះយល់ស្របថា សំណួរទាំងឡាយណាដែលមិនបានយោងទៅលើឯកសារណាមួយ ឬមិនបានយោងទៅលើចម្លើយរបស់សាក្សីណាមួយនៅ ចំពោះមុខតុលាការនេះ សំណួរនោះនឹងមិនអាចទទួលស្គាល់ថាត្រឹមត្រូវទេ ពីព្រោះតុលាការមិនបានដឹងឮ មិនបានសាកសួរ ដូច្នេះគំនិតយោបល់ដែលលើកឡើងនេះមិនអាចធ្វើទៅបានទេ។ តុលាការដំណើរការនីតិវិធីដោយយោងទៅលើភស្តុតាង យោងទៅលើចម្លើយសាក្សីដែលបានផ្តល់ពីមុនៗ សាក្សីដែលបានផ្តល់សក្ខីកម្មរួចហើយនៅចំពោះមុខតុលាការ ឬក៏យោងលើឯកសារទាំងឡាយដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ... ទាំងអស់នេះ គឺអាចប្រើដើម្បីយកមកធ្វើជាមូលដ្ឋានក្នុងការតាំងសំណួរទាំងឡាយទៅលើសាក្សី។*

ទោះបីជាយ៉ាងណា អង្គជំនុំជម្រះមិនបានចង្អុលបង្ហាញពីមូលដ្ឋានច្បាប់ជាក់លាក់ចំពោះការសម្រេចសេចក្តីនេះទេ។ សេចក្តីសម្រេចនេះ បានញាំងឲ្យមានការរិះគន់យ៉ាងខ្លាំងពីសំណាក់មេធាវី **អ៊ីនូហ្ស៊ី។** *(សូមមើល IV.គ)*

## ឃ. ភាពជឿជាក់នៃកំណត់ហេតុស្តីពីកិច្ចសម្ភាសន៍របស់សហចៅក្រមស៊ើបអង្កេត

ជាថ្មីម្តងទៀត នាសប្តាហ៍នេះ មេធាវី កាណាវ៉ាស បានទាញចំណាប់អារម្មណ៍ចំពោះ ភាពមិនស្របគ្នារវាងខ្សែអាត់សម្លេង និងកំណត់ហេតុកិច្ចសម្ភាសន៍របស់សាក្សី មាស រឿន នៅដំណាក់កាលសហចៅក្រមស៊ើបអង្កេត។[5] លោកបានថ្លែងថា យោងតាមកំណត់ហេតុ កិច្ចសម្ភាសន៍បានចាប់ផ្តើមនៅម៉ោង ១០:២០ នាទីព្រឹក និងបញ្ចប់នៅ ម៉ោង ៥:៣០នាទីល្ងាច ដូច្នេះ កិច្ចសម្ភាសន៍ប្រព្រឹត្តទៅរយៈពេល ៧ម៉ោង និង ១០នាទី ប៉ុន្តែដោយខ្សែកខ្សែអាត់សម្លេងមានរយៈពេលប្រមាណជា ២ម៉ោង និង ៤២វិនាទី ប៉ុណ្ណោះ។ មេធាវី **កាណាវ៉ាស** បានចោទសួរទៅសាក្សី ថាតើមានអ្វីកើតឡើងនៅក្នុងរយៈពេល ៥ម៉ោងទៀត ដែល *"មិនបានថតសម្លេង"*។ ព្រះរាជអាជ្ញា អាប់ឌុលឡាក់ បានជំទាស់នឹងសំណួរនោះ ពីព្រោះជាការសន្មត

ដែលថា ខ្មែរអាត់សម្លេង ៥ម៉ោង ត្រូវបានបាត់បង់ ដោយលើកឡើងថា៖

> *សំណួរនេះគឺជាការធ្វើការសន្មត់ ដែលថា ក្នុងខ្មែរអាត់បាត់ពេលវេលាដល់ទៅ ៥ម៉ោង។ ដូច្នេះ អាចមានការពន្យល់ជាច្រើន ចំពោះភាពខុសគ្នារវាងការកត់ ត្រា និងខ្មែរអាត់សម្លេង។ ការបាត់បង់ខ្មែរអាត់សម្លេង គឺហាក់ដូចជាការសន្មត់ ទុកជាមុន។ ប៉ុន្តែ សំណើរបស់សហព្រះរាជអាជ្ញា គឺថា មិនគួរឲ្យសាក្សីផ្តល់ យោបល់លើបញ្ហានេះទេ។*

មេធាវី កាណាវាស ក៏បានព្យាយាមក្នុងការបង្ហាញថា វិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេត គឺមាន លក្ខណៈមិនសមស្របទេ និងបានចោទសួរថាតើសាក្សីបានឃើញឯកសារ រួមមាន កំណត់ហេតុយក ចម្លើយរបស់សាក្សីផ្សេងទៀត មុនពេលសហចៅក្រមស៊ើបអង្កេតដាក់សំណួរដល់រូបគាត់ឬទេ។ សាក្សីបាន បញ្ជាក់ថា ក្រុមចៅ ក្រមស៊ើបអង្កេតបានអានខ្លឹមសារខ្លីៗនូវឯកសារមួយចំនួន រួមមាន ចម្លើយសារភាពរបស់ ជួ ជេត ជាដើម។ លើសពីនេះ សាក្សីបានឲ្យដឹងថា ក្នុងកំឡុងពេលនៃការធ្វើកិច្ចសម្ភាសន៍ ប្រពន្ធរបស់គាត់ បានអង្គុយក្បែរនោះ *"ដើម្បីជួយ រំឭកការចងចាំ។"* នៅក្នុងរបាយការណ៍នៃកិច្ចសម្ភាសន៍ បានបង្ហាញថា មានស្ត្រីម្នាក់អង្គុយខាងក្រោយសាក្សីនៅក្នុង ពេលសម្ភាស ប៉ុន្តែមិនមានការបញ្ជាក់ថា តើប្រពន្ធរបស់គាត់ បានឆ្លើយដោយផ្ទាល់ ឬក៏ជួយរំឭកសាក្សីក្នុងការឆ្លើយ សំណួរ។

មេធាវី កាណាវាស បានអះអាងថា តួនាទីរបស់មេធាវីការពារក្តី គឺត្រួតពិនិត្យលើដំណើរការនីតិវិធី ច្បាប់ទាំងអស់ និងបានរំឭកអង្គជំនុំជម្រះថា មេធាវីការពារក្តីមិនមានតួនាទីក្នុងការស៊ើបអង្កេតទេ ដូច្នេះ គាត់ត្រូវចោទសួរអំពីភស្តុតាងនានានៅដំណាក់កាលសហចៅក្រមស៊ើបអង្កេត។ ក្តីបារម្ភរបស់លោកមេធាវី គឺថា សាក្សីត្រូវបានរៀបចំ ឬបានផ្តល់ព័ត៌មានដែលពាក់ព័ន្ធ នៅមុនពេលចាប់ផ្តើមកិច្ចសម្ភាសន៍។ ការកត់សម្គាល់ដ៏សំខាន់មួយកាលពីប៉ុន្មានខែមុននេះ មេធាវី កាណាវាស ក៏បានទាញចំណាប់អារម្មណ៍របស់ តុលាការឲ្យផ្តោតសំខាន់ទៅលើសាក្សី ជា សាយ ដែលភរិយារបស់គាត់ បានជួយឆ្លើយសំណួរនៅក្នុងពេលធ្វើ សម្ភាសន៍នៅដំណាក់កាលចៅក្រមស៊ើបអង្កេត។[6]

## ខ. សំណួរនាំមុខសាក្សី

មេធាវី **អាន់តា ហ្គីសសេ** ដែលជាមេធាវីអន្តរជាតិការពារក្តី**ឲ្យ**ជនជាប់ចោទ **ខៀវ សំផន** បាន សួរដេញ ដោលសាក្សីនៅថ្ងៃអង្គារ ដោយប្រើប្រាស់នូវឯកសារផ្សេងៗ និងសេចក្តីថ្លែងការណ៍មុនៗរបស់ សាក្សី មាស វឿន និងសាក្សីដទៃទៀត។ ព្រះរាជអាជ្ញា អាប់ឌុលឡាក់ បានធ្វើការជំទាស់ទៅនឹងរបៀបនៃ ការតាំងសំណួររបស់លោកស្រីមេធាវី ដោយអះអាងថា មេធាវី ហ្គីសសេ បាននាំឲ្យសាក្សីមានការភ័ន្តច្រលំ ដោយសារការដកស្រង់ឯកសារ និង សេចក្តីថ្លែងការណ៍តែមួយផ្នែក។ អង្គជំនុំជម្រះនៅតែអនុញ្ញាតឲ្យមេធាវី ហ្គីសសេ បន្តសួរសំណួររបស់ខ្លួន បន្ទាប់ពី លោកស្រីមេធាវីបានឆ្លើយតបថា គាត់ព្យាយាមឲ្យមានការ បញ្ជាក់ចំណុចជាក់លាក់មួយចំនួន ដូច្នេះ ត្រូវតែដកស្រង់នូវចំណុចជាក់លាក់ ហើយសាក្សីអាចមាន ពេលវេលាក្នុងការកែតម្រូវ ប្រសិនបើលោកស្រីលើកឡើងខុសនូវចំណុចណាមួយ។

## ច. ដីកាដំណោះស្រាយពាក់ព័ន្ធនឹងអង្គហេតុមន្ទីរសន្តិសុខទួលពោធិ៍ជ្រៃ និងការបង្ហាញឯកសារ

ការដេញដោលរកហេតុផលបន្ថែមនូវផ្នែកមួយចំនួននៃដីកាដំណោះស្រាយ ដែលបានអានកាលពីថ្ងៃទី ៣-៤ តុលា ២០១២ នៅរសៀល ថ្ងៃអង្គារនេះ ក្រឡាបញ្ជីបានអាននូវកថាខណ្ឌមួយចំនួនបន្ថែមទៀតដែលមាននៅក្នុងដីកាដំណោះស្រាយពាក់ព័ន្ធនឹងមន្ទីរសន្តិសុខទួលពោធិ៍ជ្រៃ។[7] ការបន្ថែមអង្គហេតុនេះគឺអនុលោមតាមដីកាបំបែកសំណុំរឿង ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ដោយ បានកំណត់ពីអង្គហេតុ ដែលត្រូវជំនុំជម្រះ នៅក្នុងសំណុំរឿង០០២/១[8] និងអនុស្សារណៈ ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ (E163/5) ដែលពង្រីកដែនវិសាលភាព រួមមានដូចខាងក្រោម ៖

១. ការកម្ទេចប្រជាជន ១៧មេសា នៅការដ្ឋានក្នុងស្រុកកំពង់ត្រឡាចលើ (ស្រុក១២)

២. ការកម្ទេចអតីតទាហ៊ាន និងមន្ត្រីរដ្ឋការនៃរបប **លុន ណុល** នៅមន្ទីរសន្តិសុខទួលពោធិ៍ជ្រៃ និង

៣. មន្ទីរសន្តិសុខ ស-២១ និងវាលពិឃាតជើងឯក

បន្ទាប់ពីការអានអង្គហេតុមួយចំនួននៅក្នុងដីកាដំណោះស្រាយ សវនាការលើឯកសារត្រូវបានចាប់ផ្តើមដំណើរការនៅថ្ងៃពុធ សហព្រះរាជអាជ្ញាបានដាក់ឯសារដែល ពាក់ព័ន្ធនឹងបញ្ហាបីធំៗគឺ ៖

១. តួនាទីរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

២. រចនាសម្ព័ន្ធនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

៣. រចនាសម្ព័ន្ធទំនាក់ទំនង

ឯកសារទាំងនេះ រួមមាន ទស្សនាវដ្តីឃោសនាការណ៍ខ្មែរក្រហម *"ទង់បដិវត្តន៍"* - លិខិត និងរបាយការណ៍នានា ដែលបានផ្ញើមកពីការិយាល័យថ្នាក់តំបន់ និងក្រសួងនីមួយៗ - ព្រមទាំងសារទូរលេខ និងសារាចរ ណែនាំផ្សេងៗ។ ឯកសារទាំងនេះ បានបង្ហាញពីទម្រង់ និងរបៀបនៃការគ្រប់គ្រងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ - របៀបនៃការទំនាក់ទំនងជាមួយថ្នាក់ដឹកនាំនានា - និងបែបបទក្នុងការចេញ បទបញ្ជាទៅថ្នាក់ក្រោមៗ។

## ឆ. មតិយោបល់របស់លោក នួន ជា ចំពោះដំណើរការនីតិវិធី

អនុលោមតាមសំណើរបស់គាត់កាលពីសប្តាហ៍មុន ជនជាប់ចោទ **នួន ជា** ត្រូវបានផ្តល់ពេលវេលានៅព្រឹកថ្ងៃពុធ ដើម្បីធ្វើការឆ្លើយតបលើចំណុចមួយចំនួននៃដីកាដំណោះស្រាយ ក្រោយពីការអានដោយក្រឡាបញ្ជីដែល ពាក់ព័ន្ធនឹងសវនាការវគ្គទី៣ នាសប្តាហ៍នេះ។ នៅពេលដែលជនជាប់ចោទ **នួន ជា** បានចាប់ផ្តើមផ្តល់មតិយោបល់ របស់ខ្លួន ភ្លាមៗនោះ ប្រធានអង្គជំនុំជម្រះ **និល ណុន** បានក្រើនរំឭកគាត់ថា ជនជាប់ចោទត្រូវបានអនុញ្ញាតឲ្យឆ្លើយតបតែទៅលើផ្នែកទាំងឡាយដែលមានចែងក្នុងដីការដំណោះស្រាយ

និងមិនអនុញ្ញាតឲ្យផ្តល់យោបល់លើបញ្ហាផ្សេងៗឡើយ។ លើសពីនេះ ចៅក្រមនៃអង្គជំនុំជម្រះអាចនឹងសួរសំណួរមួយចំនួនទៅគាត់ទៅចំពោះមតិយោបល់ទាំងឡាយដែលលោក **នួន ជា** បានលើកឡើង ហើយថាគាត់មានជម្រើសធ្វើការឆ្លើយតប ឬមិនឆ្លើយតប។ ជាបន្ទាប់ ជនជាប់ចោទ **នួន ជា** បានប្រើប្រាស់រយៈពេល តែ ១ នាទី ប៉ុណ្ណោះ ដោយបានថ្លែងថា គាត់បដិសេធលើការចោទប្រកាន់ទាំងអស់ក្នុងដីកាដំណោះស្រាយ ដែលចោទថា គាត់មានជាប់ពាក់ព័ន្ធក្នុងការបង្កើតមន្ទីរសន្តិសុខនានា។ ជាពិសេស គាត់បានថ្លែងថា *"ខ្ញុំពុំមានតួនាទីអ្វីគ្រប់គ្រាន់លើមន្ទីរ ស-២១ទេ"* និងបានបដិសេធមិនឆ្លើយតបនូវសំណួររបស់អង្គជំនុំជម្រះ ដោយលើកហេតុផលថា ស្ថានភាពសុខភាពមិនសូវល្អ។

## IV. ការគ្រប់គ្រងសវនាការ

ថ្វីបើមានការប៉ះទង្គិច និងមានសង្គ្រាមពាក្យសំដីជាច្រើន រវាងអង្គចៅក្រម និងក្រុមមេធាវីការពារក្តីលោក **នួន ជា** ក៏អង្គជំនុំជម្រះអាចដំណើរការសវនាការទៅតាមការគ្រោងទុក។

### ក. វត្តមាន

ជនជាប់ចោទ ***អៀង សារី*** បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការ[9] ដោយសារស្ថានភាពជម្ងឺមិនទាន់បានធូរស្បើយ ហើយគាត់នៅតែបន្តសម្រាកព្យាបាលនៅមន្ទីរពេទ្យសហភាពខ្មែរ-សូវៀត និងពុំមានវត្តមាននៅក្នុងបន្ទប់សវនាការពេញមួយសប្តាហ៍នេះ។ ដូចសព្វមួយដង ជនជាប់ចោទ **នួន ជា** បានចូលរួមតាមដានសវនាការតែពេលព្រឹក និងបានលះបង់សិទ្ធិចូលរួមនៅពេលរសៀល ដោយសារតែភាពឆាប់ហត់នឿយអស់កម្លាំង និងការឈឺឆ្អឹងខ្នង។ ដោយឡែក មានតែជនជាប់ចោទ ***ខៀវ សំផន*** ដែលមានវត្តមាននៅក្នុងបន្ទប់សវនាការពេញមួយសប្តាហ៍។

**ការចូលរួមពីសាធារណជន ៖**

| កាលបរិច្ឆេទ | សវនាការពេលព្រឹក | សវនាការពេលរសៀល |
|---|---|---|
| ថ្ងៃច័ន្ទ ០៨/១០/១២ | ▪ សិស្សានុសិស្សជាង ២៥០នាក់ មកពីខេត្តបាត់ដំបង<br>▪ អ្នកសង្កេតការអន្តរជាតិ ១០នាក់ | ▪ ប្រជាពលរដ្ឋជាង ១០០នាក់ មកពីខេត្តកំពង់ចាម<br>▪ អ្នកសង្កេតការអន្តរជាតិ ១០នាក់ |
| ថ្ងៃអង្គារ ០៩/១០/១២ | ▪ សិស្សានុសិស្សជាង ៤០០នាក់ មកពីខេត្តកំពង់សោម<br>▪ អ្នកសង្កេតការអន្តរជាតិ ២០នាក់ | ▪ ប្រជាពលរដ្ឋជាង ១០០នាក់ មកពីខេត្តកំពង់ចាម |
| ថ្ងៃពុធ ១០/១០/១២ | ▪ ប្រជាពលរដ្ឋជាង ២៥០នាក់ មកពីខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង និងខេត្តកំពត | ▪ ប្រជាពលរដ្ឋជាង ១០០នាក់ មកពីខេត្តកំពង់ចាម<br>▪ អ្នកសង្កេតការអន្តរជាតិ ១០នាក់ |

## ខ. ការគ្រប់គ្រងពេលវេលា

អង្គជំនុំជម្រះបានបញ្ចប់ការស្ដាប់សក្ខីកម្មសាក្សី មាស វឿន មុនការគ្រោងទុក ពោលគឺត្រឹមម៉ោង ៣:៣៥ នៅរសៀលថ្ងៃអង្គារ។ អង្គជំនុំជម្រះប្រើប្រាស់ពេលវេលាដែលនៅសេសសល់ ដោយបានណែនាំឲ្យក្រឡាបញ្ជី ឲ្យអាននូវកថាខណ្ឌមួយចំនួននៅក្នុងដីកាដំណោះស្រាយពាក់ព័ន្ធនឹងបទចោទប្រកាន់នៃការសម្លាប់អតីតទាហាន លន់ ណុល នៅមន្ទីរសន្តិសុខទួលពោធិ៍ជ្រៃ។ នៅព្រឹកថ្ងៃបន្ទាប់ និងក្រោយពីបញ្ចប់ការអានដីកាដំណោះស្រាយលោក **នួន ជា** បាន ទទួលការអនុញ្ញាតឲ្យធ្វើសេចក្ដីថ្លែង**តប**ចំពោះបទចោទប្រកាន់មកលើខ្លួន។ ទោះបីជាយ៉ាងណាលោក **នួន ជា** បានធ្វើការសម្ដែងមតិតែពីរទៅបីនាទីប៉ុណ្ណោះ។ ដោយហេតុនេះ សវនាការលើឯកសារត្រូវបានចាប់ផ្ដើមដំណើរការនៅថ្ងៃពុធ សហព្រះរាជអាជ្ញាបានចំណាយពេលពេញមួយថ្ងៃក្នុងការដាក់បង្ហាញឯកសាររបស់ខ្លួន។ អង្គជំនុំជម្រះមិនធ្វើសវនាការនៅថ្ងៃព្រហស្បតិ៍ ទី១១ ខែតុលា ទេ ដោយសារតែពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិបានខិតកៀកមកដល់ និងបានប្រកាសផ្អាកដំណើរការនីតិវិធីរហូតដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១២។

## គ. ឥរិយាបថនៅក្នុងបន្ទប់សវនាការ

សង្គ្រាមពាក្យសម្ដីជាបន្តបន្ទាប់ រវាងអង្គចៅក្រម និងមេធាវី អ៊ីនូហ្សី បានគ្របដណ្ដប់ ដំណើរការសវនាការ ពេញមួយសប្ដាហ៍។ នៅចុងសវនាការព្រឹកថ្ងៃច័ន្ទ នៅពេលមេធាវី អ៊ីនូហ្សី សុំការអនុញ្ញាតដាក់សំណើរបស់ខ្លួន ប្រធានអង្គជំនុំជម្រះបានតម្រូវឲ្យមេធាវីកំណត់នូវចំណុចបញ្ហា ដើម្បីឲ្យអង្គជំនុំជម្រះមានមូលដ្ឋានក្នុងការសម្រេច ថាតើអនុញ្ញាត ឬមិនអនុញ្ញាត? ដោយលើកឡើងថា *"អង្គជំនុំជម្រះបានកត់សម្គាល់ថាលោកមេធាវីកម្រនឹងប្រព្រឹត្តតាមការណែនាំ និងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះណាស់។"* មេធាវី អ៊ីនូហ្សី បានប្រងើយកន្តើយនឹងការណែនាំនេះ និងបានថ្លែង *"ទុកជាប្រតិចារិក"* ដោយជោគជ័យ ដោយដកស្រង់សេចក្ដីថ្លែងការណ៍ ដែលគាត់បានលើកឡើងកាលពីសប្ដាហ៍មុន ប៉ុន្តែក្រោយមក *"ត្រូវបានលុបចោល"*។ សំណើរដែលគាត់បានថ្លែងគឺ៖

> *នេះគឺជាសេចក្ដីស្នើសុំដោយផ្ទាល់មាត់របស់ខ្ញុំ។ ខ្ញុំគិតថា ដើម្បីឲ្យមានភាពស្មើគ្នា យើងគួរស្ដាប់សហភាតារបស់ខ្ញុំនៅក្នុងតំណាក់កាលនេះ និងពីសហព្រះរាជ-អាជ្ញា ហើយជាបន្ទាប់ លោក/លោកស្រីចៅក្រមនឹងធ្វើសេចក្ដីសម្រេចដោយផ្ទាល់មាត់។ ខ្ញុំឃើញថា ពេលនេះ លោក/លោកស្រីចៅក្រមបានងើបដើរចេញពីបន្ទប់សវនាការ ប៉ុន្តែក្នុងនាមជាចៅក្រម ត្រូវតែដោះស្រាយបញ្ហាដែលកើតមានឡើង។ ខ្ញុំសូមបញ្ជាក់ថា នៅពេលដែលលោកចៅក្រមបានដើរចេញទៅក្រៅនោះ គឺមិនអាចដោះស្រាយបាននោះទេ។*

ជាលទ្ធផល ប្រធានអង្គជំនុំជម្រះ និល ណុន បានចុចផ្ដាច់ម៉ៃក្រូហ្វូនសម្លេង និងសួរបញ្ជាក់ថាតើមេធាវី អ៊ីនូហ្សី មានបញ្ហាអ្វីផ្សេងទៀតនឹងលើកឡើងឬទេ។ បន្ទាប់មក មេធាវី អ៊ីនូហ្សី បានសុំការបញ្ជាក់អំពី *"ការលុបចោល"* សេចក្ដីថ្លែងការណ៍របស់គាត់ចេញពីប្រតិចារិក។ កាលពីសប្ដាហ៍មុន លោកស្រីចៅក្រម ខាតរ៉ាយច៍ បានថ្លែងថា ក្របខណ្ឌច្បាប់របស់ *អ.វ.ត.ក.* *"មិនបានកំណត់ពីការលុបចោល ដើម្បីជា*

*ដំណោះស្រាយនោះទេ"* ហើយលោកស្រីក៏បាន បដិសេធសំណើ សុំឲ្យលុបចោលចំណុចមួយចំនួន ចេញពីសេចក្តីថ្លែងការណ៍របស់សាក្សី មាស វឿន ដែលសហចៅក្រមស៊ើបអង្កេតបានយោងលើចម្លើយសារភាពទទួលបានពីទារុណកម្ម។ ទោះបីជាយ៉ាងណា មេធាវី អ៊ីនូហ្ស៊ី បានបន្តថា កាលពីថ្ងៃ ទី៥ ខែតុលា ឆ្នាំ២០១២ លោកស្រីចៅក្រម ខាត់រ៉ាយថ៍ *"បានចេញដីកា និងចុះហត្ថលេខាលុបចោលចំណុចនេះនៅក្នុងប្រតិចារិក[10] ដូច្នេះ ខ្ញុំពិតជាវង្វេងវង្វាន់ ខ្ញុំពិតជាវង្វេងវង្វាន់ខ្លាំងណាស់។"*

ជាបន្ទាប់ មេធាវី អ៊ីនូហ្ស៊ី បានដកស្រង់សេចក្តីបង្គាប់របស់ចៅក្រម ដេវីដ ហាន់ថ៍ ពីតុលាការព្រហ្មទណ្ឌអន្តរជាតិប្រទេសយូហ្គោស្លាវី ICTY (ដែលគាត់បានដកស្រង់បន្តចេញពីអត្ថបទរបស់ លេវីស ខារ៉ូល មានចំណងជើង ថា *ឆ្លុះមើលកញ្ចក់* (*Looking Glass*)។ លោកចៅក្រមបានលើកឡើងដូចតទៅ ចំពោះការប្រើប្រាសភាសាច្បាប់ ៖

> *ខ្ញុំដឹងនូវច្បាប់អនុញ្ញាតមួយ ដែលប្រហែលជាអាចបង្ហាញភាពសមហេតុផលនូវរបៀបរបបដែលបានស្នើសុំ។ "នៅពេលខ្ញុំប្រើពាក្យមួយ" ដែលខ្ញុំបាននិយាយស្តាប់ទៅក្នុងលក្ខណៈមួយដោយសម្លេងធ្ងន់ៗ "នោះវាមានន័យនូវអ្វីដែលយើងគិតថា អាក្រក់ ឬល្អ វាអាចនឹងលើស ឬខ្វះ (មែន ឬមិនមែន ត្រូវ ឬមិនត្រូវ) នូវចំណុចទាំងពីរនេះ។" សំណួរសួរថា តើអ្នកជាអ្នកបង្កើតពាក្យពេជទាំងឡាយដែលមានអត្ថន័យច្រើនបែប ច្រើនសណ្ឋានឬយ៉ាងណា សួរថាតើការ ដែលបាននិយាយពីនេះពីនោះ ដែលនាំឲ្យក្លាយខ្លួនជាប្រធានធំ តែប៉ុណ្ណឹងឬយ៉ាងណា?*

ប្រធាន**អង្គជំនុំជម្រះ** និល ណុន បានកាត់ផ្តាច់ម៉ៃក្រូហ្វូន**សម្លេង**របស់មេធាវី អ៊ីនូហ្ស៊ី ជាលើកទីពីរ និងបាន**ថ្លែង**ថា *"ចំណុចនេះមាននៅក្នុងកំណត់ត្រាក្នុងប្រតិចារិកហើយ ដែលយើងជាប្រធានសាលាដំបូងមិនអនុញ្ញាតឲលោកមេធាវីលើកបញ្ហានេះទៀតទេ។"* ក្រោយមក ម៉ៃក្រូហ្វូនសម្លេងរបស់លោកមេធាវីត្រូវបានកាត់ ផ្តាច់ម្តងទៀត នៅពេលដែលគាត់មានចេតនាចង់បញ្ចប់ការដកស្រង់របស់ខ្លួនកាលពីព្រឹកមិញ។

ក្នុងកំឡុងពេលសួរដេញដោលសាក្សីដោយមេធាវី **អ៊ីនូហ្ស៊ី** នៅថ្ងៃអង្គារ អង្គជំនុំជម្រះបានបដិសេធមិន អនុញ្ញាតឲ្យមេធាវីរូបនេះសួរសំណួរសាក្សីដោយផ្អែកលើ *"មតិយោបល់"* **និង**មិនយោងលើឯកសារ ឬសេចក្តីថ្លែងការណ៍ជាក់លាក់ណាមួយ *(សូមមើល III.**គ**)*។ មេធាវី **អ៊ីនូហ្ស៊ី** បានសម្តែងនូវការជំទាស់ដោយបានលើកឡើងថា *"ខ្ញុំដឹងថា អង្គជំនុំជម្រះហាក់ដូចជាពេញចិត្តការច្នៃប្រឌិត"* ប៉ុន្តែ *"មតិយោបល់ពាក់ព័ន្ធទៅនឹងព័ត៌មាន ពាក់ព័ន្ធទៅនឹងមនុស្សដែលខ្ញុំលើកឡើងនោះ គឺថា យើងមានព័ត៌មានអាចសួរបានក្រៅពីឯកសារ។"* មេធាវីបានបន្ថែមថា *"យើងមានតុលាការនេះនៅលើក្រដាស យើងនឹងមានការកត់ត្រានៅលើក្រដាសនៅក្នុងប្រតិចារិក។ តើនៅលើផែនដីនេះ លោកស្រីចៅក្រម ខាត់រ៉ាយថ៍! តើលោកស្រីចៅក្រមអាចរកលក្ខខណ្ឌគតិយុត្តិមកគាំទ្រនូវសេចក្តីសម្រេចខ្លួនឬទេ?"*

បន្ថែមលើនេះ នៅថ្ងៃអង្គារ មេធាវី អ៊ីនូហ្ស៊ី បានធ្វើកំណត់ហេតុយោងលើព្រឹត្តិការណ៍ថ្មីៗនៅក្នុងប្រទេសកម្ពុជា ក្នុងការសួរដេញដោលសាក្សី ដែលសុំឲ្យគាត់បញ្ចេញគំនិតយោបល់លើករណី លោក ម៉ម សូណាន់ដូ (សកម្មជនសិទ្ធិមនុស្ស និងជាប្រធានវិទ្យុសម្បុកឃ្មុំ)។ ប្រធានអង្គជំនុំជម្រះបានកាត់ផ្តាច់ម៉ៃក្រូហ្វូនសម្លេង និងបានរារាំងមេធាវីមិនឲ្យបន្តលើកបញ្ហានេះ ដោយហេតុផលថា វាមិនជាប់ពាក់ព័ន្ធ។

ប្រហែលជាការឆ្លើយតបទៅចៅក្រម ខាតរ៉ាយថ៍ កាលពីព្រឹកមិញ ដែលពាក់ព័ន្ធនឹងការសួរសំណួរយោងលើឯកសារ ឬមតិយោបល់[11] ក្នុងចំណុចនេះ មេធាវី អ៊ីនួហ្សុី បានបញ្ចប់ការសួរដេញដោលរបស់ខ្លួនដោយបានលើក ជាយោបល់នៅមានការងឿងឆ្ងល់ថា *"ប្រហែលជាខ្ញុំនឹងបញ្ចប់ដោយការព្រមព្រៀងជាមួយ លោក វីឆាដ រូជើរស៍ ខ្ញុំកំពុងសំដៅទៅលើតន្ត្រីករដ៏ល្បីម្នាក់ មិនមែនជាមេធាវីដ៏ល្បីល្បាញនោះទេ វាមិនដូចជាស្ត្រីដែលមានសក្តិខ្ពស់ឡើយ។"*

នៅចុងបញ្ចប់សវនាការថ្ងៃអង្គារ អង្គជំនុំជម្រះបានចេញសេចក្តីព្រមានមួយប្រឆាំងនឹងមេធាវី អ៊ីនួហ្សុី ដោយមូលហេតុពាក់ព័ន្ធនឹង *"ការមិនគោរព"* និងការធ្វើសេចក្តីថ្លែងការណ៍ *"ប្រមាថមើលងាយ។"*[12] គួររំឭកថា កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីព្រមានមួយដល់មេធាវី អ៊ីនួហ្សុី និងសហភាតារបស់គាត់ គឺលោកមេធាវី ម៉ៃឃើល ផេស្តមេន ដែលជាមេធាវីការពារក្តីអន្តរជាតិរបស់ជនជាប់ចោទ **នួន ជា**។[13] នៅក្នុងសេចក្តីសម្រេចសប្តាហ៍នេះ អង្គជំនុំជម្រះបានចង្អុលបង្ហាញថា សកម្មភាពរបស់មេធាវី **អ៊ីនួហ្សុី** បានក្លាយទៅជា *"កិរិយាមិនត្រឹមត្រូវខុសនឹងវិជ្ជាជីវៈ។"* វិធាន ៣៨(១) នៃវិធានផ្ទៃក្នុង បានកំណត់ដូចខាងក្រោម ៖

> *សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ក្រោយពេលព្រមាន អាចដាក់ទណ្ឌកម្ម ឬបដិសេធក្នុងការចូលរួមសវនាការចំពោះមេធាវីណាមួយ ប្រសិនបើយល់ឃើញថា ការប្រព្រឹត្តរបស់មេធាវីរូបនោះ ជាកាប្រមាថមើលងាយ រាំងស្ទះដល់ដំណើរការនីតិវិធី រំលោភទៅលើងរឿងក្តី ឬផ្ទុយទៅនឹងមាត្រា២១-៣ នៃកិច្ចព្រមព្រៀង។*

លើសពីនេះ អង្គជំនុំជម្រះក៏បានថ្លែងថា ការប្រព្រឹត្តទាំងនេះនឹងត្រូវដាក់ជូនដល់គណៈមេធាវីរបស់លោក មេធាវី ព្រមជាមួយនឹងសេចក្តីសម្រេចមុន។ ថ្វីបើអង្គជំនុំជម្រះបានចេញសេចក្តីព្រមានយ៉ាងនេះក្តី នៅថ្ងៃបន្ទាប់ មេធាវី **អ៊ីនួហ្សុី** បានស្ម័គ្រចិត្តថា នឹងទទួលយក *"បណ្តឹងនេះ"* ទៅប្រគល់ឲ្យគណៈមេធាវីនៅទីក្រុងញ៉ូវយ៉កដោយផ្ទាល់ ដោយសារគាត់នឹងត្រឡប់ទៅវិញនៅចុងខែនេះ។ ប្រធានអង្គជំនុំជម្រះ បានឆ្លើយតបថា អង្គជំនុំជម្រះមានមធ្យោបាយគ្រប់គ្រាន់ក្នុងបញ្ជូនពាក្យបណ្តឹងនេះ។

## ឃ. បញ្ហាបច្ចេកទេស និងបញ្ហាអក្ខរាវិរុទ្ធ

មុនចាប់ផ្តើមសវនាការនៅថ្ងៃអង្គារ មេធាវី អាន់តា ហ្គីសសេ បានទាញចំណាប់អារម្មណ៍ពីការភ័ន្តច្រឡំ មួយ ដោយថ្លែងថា យោងតាមសេចក្តីព្រាងប្រតិចារិក ចុះថ្ងៃទី៨ ខែតុលា ចំណុចដែលចៅក្រម ឡាវែន៍ បានយោងទៅលើកំណត់ហេតុកិច្ចប្រជុំមួយដែលបានប្រព្រឹត្តទៅនៅថ្ងៃ១៨ មីនា ១៩៧៦។ លោកស្រីមេធាវី ហ្គីសសេ បានស្នើថា ចៅក្រម ឡាវែន៍ បានលើកឡើងថា កុយ ធួន មានវត្តមាននៅ ក្នុងកិច្ចប្រជុំនោះ ប៉ុន្តែនៅពេលលោកស្រីបានពិនិត្យមើលបញ្ជីឈ្មោះអ្នកចូលរួមនៅក្នុងប្រតិចារិក គឺជាឈ្មោះ ភួក ឆាយ ហៅ *"ទូច"* មិនមែន កុយ ធួន ហៅ *"ធុច"* ទេ។ មេធាវី ហ្គីសសេ បានសង្កត់ធ្ងន់ទៅ លើសារៈសំខាន់នៃការបញ្ចេញសម្លេងឲ្យបានត្រឹមត្រូវពីអក្ខរាវិរុទ្ធដើម្បីជាប្រតិចារិក និងជៀសវាងការភ័ន្តច្រឡំ។ នាពេលនោះ

ចៅក្រម ឡាវែន៍ បានចោទសួរលោកស្រីមេធាវី ថាតើគាត់បានពិនិត្យទៅលើភាសាខ្មែរ និងភាសាបារាំងដែរឬទេ? មេធាវី ហ្គីសសេ បានបញ្ជាក់ពីភាពខុសគ្នារវាងភាសាទាំងពីរ។

ចំណែកបញ្ហាបច្ចេកទេសវិញ មានពេលមួយ ប្រព័ន្ធសម្លេងនៃការបកប្រែមិនមានដំណើរការ ហើយអ្នកបច្ចេកទេសបានជម្រាបជូនអង្គជំនុំជម្រះថា វាអាចចំណាយពេលបន្តិចក្នុងការជួសជុលឡើងវិញ។ ប្រហែលជា ៥នាទីក្រោយមក បញ្ហានេះក៏ត្រូវបានដោះស្រាយ និងបានដំណើរការដោយពុំមានរអាក់រអួល។

## ខ. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាកពេលរសៀល | បញ្ចប់សវនាការ | រយៈពេលសវនាការសរុប |
|---|---|---|---|---|---|---|
| ថ្ងៃច័ន្ទ ០៨/១០/១២ | ៩.០៣ | ១០.៣៣-១០.៥៣ | ១២.០៦-១៣.៣០ | ១៤.៤២-១៥.០២ | ១៦.០៤ | ៤ ម៉ោង និង ៥៧ នាទី |
| ថ្ងៃអង្គារ ០៩/១០/១២ | ៩.០២ | ១០.៣៨-១១.០២ | ១២.១៣-១៣.៣៣ | ១៤.៤២-១៥.១០ | ១៦.១៣ | ៤ ម៉ោង និង ៥៩ នាទី |
| ថ្ងៃពុធ ១០/១០/១២ | ៩.០៩ | ១០.៣៦-១០.៥៩ | ១២.០៥-១៣.៣២ | ១៤.៣៩-១៥.០១ | ១៥.០២ | ៤ ម៉ោង និង ៤១ នាទី |
| រយៈពេលសវនាការជាមធ្យម | | | | ៤ ម៉ោង និង ៥២ នាទី | | |
| រយៈពេលសវនាការសរុបក្នុងសប្តាហ៍នេះ | | | | ១៤ ម៉ោង និង ៣៧ នាទី | | |
| ចំនួនសរុបនៃម៉ោង ថ្ងៃ និង សប្តាហ៍ នៃសវនាការ | | | | ៥១៤ ម៉ោង និង ១៩ នាទី | | |
| រយៈពេលសវនាការចំនួន ១១៧ថ្ងៃ អំឡុងពេល ៣៥ សប្តាហ៍ | | | | | | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"* (Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

EAST-WEST CENTER

AIJI TRIAL MONITORING

WCSC WAR CRIMES STUDIES CENTER UNIVERSITY OF CALIFORNIA, BERKELEY

* AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of **KRT TRIAL MONITOR** was authored by Kimsan Soy, Sovanna Sek, Samantha Lee, Faith Suzzette Delos Reyes, and Penelope Van Tuyl, as part of AIJI's KRT Trial Monitoring and Community Outreach

Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

[1] *See* CASE 002 KRT TRIAL MONITOR. Issue No. 38, Hearing on Evidence Week 33 (1-4 October 2012). 9.

[2] Ibid, 10.

[3] IR 55 (7) states: A written record shall be made of every interview. Each page of the written record shall be signed or fingerprinted after the interviewee reads it. If necessary, the Greffier of the Co- Investigating Judges, with the assistance of the interpreter, shall read the record back. If the interviewee refuses to sign or fingerprint the record, the Greffier of the Co-Investigating Judges shall note this on the record.

[4] CASE 002 KRT TRIAL MONITOR. Issue No. 38, Hearing on Evidence Week 33 (1-4 October 2012). 10.

[5] *See e.g.* CASE 002 KRT TRIAL MONITOR. Issue No. 27. Hearing on Evidence Week 22 (19-21 June 2012). 13; *and* CASE 002 KRT TRIAL MONITOR. Issue No. 35, Hearing on Evidence Week 30 (3-6 September 2012). 7-8.

[6] CASE 002 KRT TRIAL MONITOR. Issue No. 36, Hearing on Evidence Week 31 (20-21 September 2012). 6.

[7] IR 89 *bis.* states: The President shall order the Greffiers to read the counts against the Accused and may order the Greffier to read the factual analysis in the Indictment.

[8] Paragraph 1 includes the following matters: a) The structure of Democratic Kampuchea; b) Roles of each Accused during the period prior to the establishment of Democratic Kampuchea, including when these roles were assigned; c) Role of each Accused in the Democratic Kampuchean government, their assigned responsibilities, the extent of their authority and the lines of communication throughout the temporal period with which the ECCC is concerned; and d) Policies of Democratic Kampuchea on the issues raised in the Indictment. Paragraph 5 lists the following: a) Factual allegations described in the Indictment as population movement phases 1 and 2; and b) Crimes against humanity including murder, extermination, persecution (except on religious grounds), forced transfer and enforced disappearances (insofar as they pertain to the movement of population phases 1 and 2). Trial Chamber. "Severance Order Pursuant to Internal Rule 89*ter*"(22 September 2011). E124.

[9] In accordance with Internal Rule 81 (1) and Articles 14 (1) and 14 (3) (d) of the International Covenant for Civil and Political Rights, Accused Ieng Sary issued a Limited Waiver, agreeing to waive his direct presence in the courtroom for 1 Civil Party and 7 witnesses. He explicitly stated that he is not waiving his right to be present for other witnesses. *See* Ieng Sary. "Limited Waiver" (18 September 2012). E229. Due to his extended stay in the hospital, he subsequently issued another Limited Waiver for 11 additional witnesses and 7 Civil Parties. *See* Ieng Sary. "Limited Waiver" (1 October 2012). E237.

[10] The document concerns the record of the hearing on 3 October and "orders the removal… of the words spoken by the Defence Counsel for Nuon Chea after the adjournment of the morning session the hearing. As the hearing was adjourned, these words were improperly recorded." Trial Chamber. "Order to Strike Words from the Record/Public" (5 October 2012). E1/129/1.

[11] During the first session, Judge Cartwright issued the ruling for the Chamber that Parties, must base their questions on documents or other verifiable sources against which the Chamber might test the oral evidence. Ianuzzi responded, "I haven't been a lawyer for very long, but that certainly, certainly sounds to me like an absolutely incorrect statement of what's…" Ianuzzi was then cut off and he and Judge Cartwright exchanged half sentences, speaking over each other, until the President cut them off. This was when Judge Cartwright said, "You have been told before, you do not comment…", and Ianuzzi said, "…Where on earth, Judge Cartwright, did you find the legal support for the ruling…" At this point the President cut them off and encouraged Ianuzzi to move on with his questioning. *See also* previous paragraph and III.C.

[12] Trial Chamber. "Continuing professional misconduct of lawyer admitted to your Bar Association" (18 October 2012). E 214/2.

[13] Trial Chamber. "Professional misconduct of lawyer[s] admitted to your Bar Association" (29 June 2012). E214/1. *See also*, CASE 002 KRT TRIAL MONITOR. Issue No. 27. Hearing on Evidence Week 22 (19-21 June 2012). 15.